# ការដាច់ចរន្តអគ្គិសនីក្រោយទឹកជំនន់

## ព័ត៌មានស្ដីពីការដាច់ចរន្តអគ្គិសនីក្រោយទឹកជំនន់

**Khmer | ភាសាខ្មែរ**

**OFFICIAL**

វាអាចចំណាយពេលមួយចំនួនដើម្បីឱ្យមានចរន្តអគ្គិសនីឡើងវិញ ក្រោយទឹកជំនន់។ ប្រើគន្លឹះខាងក្រោមលើកិច្ចការមួយចំនួនដែលអ្នកអាចធ្វើបាន ប្រសិនបើមានការដាច់ចរន្តអគ្គិសនី។

## គន្លឹះស្ដីពីការរក្សាម្ហូបអាហាររបស់អ្នកឱ្យមានសុវត្ថិភាព

- ការដាច់ចរន្តអគ្គិសនីអាចប៉ះពាល់ដល់ម្ហូបអាហាររបស់អ្នក សូមចងចាំត្រូវ៖
  - ✓ ផ្ទេរម្ហូបអាហារពីទូទឹកកក ទៅទូធ្វើឱ្យកក
  - ✓ រក្សាម្ហូបអាហាររបស់អ្នកឱ្យត្រជាក់ដែលអាចធ្វើទៅបាន ដោយដាក់ថង់ទឹកកក ឬគ្របភួយទប់ធាតុត្រជាក់លើកញ្ចប់ម្ហូបអាហារ
  - ✓ ប្រសិនបើម្ហូបអាហាររបស់អ្នកនៅតែត្រជាក់នៅពេលប៉ះ (តិចជាង 5 °C) នោះវាមានសុវត្ថិភាពដើម្បីប្រើប្រាស់
  - ✓ ប្រសិនបើម្ហូបអាហាររបស់អ្នកលែងត្រជាក់នៅពេលប៉ះ នោះអ្នកអាចរក្សាទុក និងបរិភោគវាបានរហូតដល់ទៅបួនម៉ោង ហើយបន្ទាប់ពីនោះត្រូវតែបោះចោលវា ឬត្រូវចម្អិន និងបរិភោគ
  - ✓ បរិភោគអាហារនៅក្ដៅៗក្នុងរយៈពេលបួនម៉ោងក្រោយកម្ដៅវា ឬបោះវាចោល
  - ✓ ប្រសិនបើមានចរន្តអគ្គិសនីវិញនៅពេលអាហារបង្កកនៅកករឹង នោះអាហារមានសុវត្ថិភាពដើម្បីបង្កកឡើងវិញបាន។

## គន្លឹះស្ដីពីការប្រើម៉ាស៊ីនភ្លើង

- ម៉ាស៊ីនភ្លើងត្រូវបានប្រើជាទូទៅ នៅពេលដាច់ចរន្តអគ្គិសនី។ ប្រើប្រាស់គន្លឹះទាំងនេះនៅមុនពេលអ្នកប្រើម៉ាស៊ីនភ្លើង៖
  - ✓ ធ្វើឱ្យប្រាកដថាម៉ាស៊ីនភ្លើងប្រើប្រេងសាំង ឬប្រេងម៉ាស៊ូត ត្រូវបានប្រើនៅកន្លែងខាងក្រៅអគារដែលមានខ្យល់ចេញចូលល្អ បើមិនដូច្នេះទេវាអាចបណ្ដាលឱ្យមានការពុលដោយឧស្ម័នម៉ូណូអ៊ុកស៊ីតកាបោន ដែលអាចធ្វើឱ្យអ្នកឈឺខ្លាំង
  - ✓ មិនត្រូវប្រើម៉ាស៊ីនភ្លើងចល័ត ឬម៉ាស៊ីនភ្លើងសម្រាប់ប្រើនៅខាងក្រៅអគារ នៅខាងក្នុងផ្ទះរបស់អ្នកទេ ពីព្រោះវាអាចបណ្ដាលឱ្យមានការពុលដោយឧស្ម័នម៉ូណូអ៊ុកស៊ីតកាបោន ការឆក់អគ្គិសនី ឬភ្លើងឆេះ
  - ✓ ដំឡើងម៉ាស៊ីនភ្លើងជាអចិន្ត្រៃយ៍ ដ្បិតអីវាសមស្របបំផុតជាថាមពលបម្រុង
  - ✓ រក្សាម៉ាស៊ីនភ្លើងរបស់អ្នកស្ថិតនៅក្នុងកន្លែងស្ងួត។ អ្នកគួរស្តុកទុកប្រេងសាំងនៅខាងក្រៅអគារ ក្នុងកន្លែងដែលបានការពារ
  - ✓ សម្ងួតដៃរបស់អ្នក មុននឹងប៉ះម៉ាស៊ីនភ្លើង
  - ✓ ពិនិត្យមើលថាការតខ្សែភ្លើង ឬការដំឡើងគ្រឿងអគ្គិសនីផ្សេងទៀតមិនមានខូចខាតអ្វីទេ មុនពេលអ្នកបើកម៉ាស៊ីនភ្លើង
  - ✓ បិទ និងធ្វើឱ្យត្រជាក់ម៉ាស៊ីនភ្លើង មុនពេលចាក់សាំងបំពេញ។ ប្រេងសាំងដែលកំពប់នៅលើផ្នែកនៃម៉ាស៊ីនដែលក្ដៅ អាចបណ្ដាលឱ្យឆាបឆេះភ្លើង
  - ✓ ដោតឌុយឧបករណ៍ទៅក្នុងម៉ាស៊ីនភ្លើង ដោយប្រើខ្សែភ្លើងតសម្រាប់ការងារធ្ងន់ៗ
  - ✓ កុំព្យាយាមតអគ្គិសនីទៅផ្ទះតាមខ្សែដោយដោតឌុយម៉ាស៊ីនភ្លើងទៅក្នុងឌុយដោតភ្លើងនៅលើជញ្ជាំង។

## ទទួលបានជំនួយ

- សម្រាប់ព័ត៌មានស្ដីពីការប្រើប្រាស់ឧស្ម័ន ឬអគ្គិសនីប្រកបដោយសុវត្ថិភាព សូមទាក់ទងសុវត្ថិភាពថាមពលរដ្ឋវិចថូរៀ (Energy Safe Victoria) តាមលេខ 9203 9700 ឬចូលមើល៖ www.esv.vic.gov.au
- ដើម្បីរាយការណ៍ពីការលេចធ្លាយឧស្ម័ន សូមហៅទូរសព្ទទៅលេខ 132 771។

ដើម្បីទទួលបានការបោះពុម្ពផ្សាយនេះជាទម្រង់ដែលអាចចូលប្រើប្រាស់បាន សូមអ៊ីមែលទៅ pph.communications@health.vic.gov.au